**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

**សាលក្រមរដ្ឋប្បវេណី**

-សំណុំរឿងរដ្ឋប្បវេណីលេខៈ ៥៨៧
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១
-សាលក្រមលេខៈ ០០៣ (ឥ)
ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២២

**សាលក្រម**
**ក្នុងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើមចោទឈ្មោះ [redacted] **សោភា** ភេទស្រី អាយុ ៤៤ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាន [redacted]។

ដោយមានអ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

សហចុងចម្លើយឈ្មោះ [redacted] **កញ្ញា** ភេទស្រី អាយុ ៦៨ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាន [redacted] ដោយមានអ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted]។

និងសហចុងចម្លើយឈ្មោះ [redacted] **សុន** និងប្រពន្ធឈ្មោះ [redacted] **គឿន** ដោយមានអ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] និងលោកស្រី [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

**១. ខ្លឹមសារនៃសាលក្រមដែលទាមទារឲ្យតុលាការចេញ៖**

**ខ្លឹមសារសាលក្រមដែលភាគីដើមចោទទាមទារឱ្យតុលាការចេញ៖**

១.១.លុបចោល កិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់លេខៈ ១២៦០សរល ចុះថ្ងៃទី ១៨/០៨/២០១១ ។

១.២.លុបចោល កិច្ចសន្យាលក់ផ្ដាច់លេខៈ០០៥/១៥សរល ចុះថ្ងៃទី ២៣/០១/២០១៥។

១.៣.លុបចោល គំនូសបង្ហាញទីតាំងដីរបស់ឈ្មោះ [redacted] កញ្ញា ចុះថ្ងៃទី ០៣/០៤/២០១៤។

១.៤.លុបចោល កិច្ចសន្យាលក់ផ្ដាច់លេខៈ១៣៩ សរល ចុះថ្ងៃទី ០៣/០៤/២០១៤។

១.៥.លុបចោល គំនូសបង្ហាញទីតាំងដីរបស់ឈ្មោះ [redacted] កញ្ញា ចុះថ្ងៃទី ០៣/០៤/២០១៤។



Scanned with CamScanner

១.៦.លុបចោល លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៣/០៤២០១៤។

១.៧.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខៈ៣៤៥/១៥ ចុះថ្ងៃទី ៣១/១២/២០១៥។

១.៨.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខៈ៣៤៥/១៥ ចុះថ្ងៃទី ៣១/១២/២០១៥។

១.៩.លុបចោល លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីលេខៈ១៤៧៧ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៧៨ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៧៩ ស.រ.ល ចុះថ្ងៃទី ២៥/ ០៩/២០២០, ១៤៨០ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៨១ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០។

១.១០.សុំសិទ្ធិកម្មសិទ្ធិលើដីទំហំ ៥៣.២២៥ (ប្រាំម៉ឺនបីពាន់ពីររយម្ភៃប្រាំ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

១.១១.សុំសិទ្ធិកម្មសិទ្ធិលើដីទំហំ ៦៩.៥៥៦,៤៧ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបប្រាំមួយ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

១.១២.សុំសំណងជម្ងឺចិត្ត និងសោហ៊ុយក្តីពីចុងចម្លើយសរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាម៉េរិក។

**២. ការសង្ខេបអំពីរឿងក្តី**

ដើមចោទបានដាក់ពាក្យបណ្តឹងនៅថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០២១ ដោយបានស្នើសុំឱ្យតុលាការចេញសាលក្រមដូចខាងលើ ដោយផ្អែកថាដើមចោទបានខ្ចីលុយលើកទីមួយពីឈ្មោះ គីង កញ្ញា ចំនួន៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាម៉េរិក ដោយដាក់បញ្ចាំដីមួយកន្លែងទំហំ ៥៣.២២៥ (ប្រាំម៉ឺនបីពាន់ពីររយម្ភៃប្រាំ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលធ្វើជាកិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់ និងលើកទីពីរ ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាម៉េរិក ដោយដាក់បញ្ចាំដីមួយកន្លែងទៀតទំហំ ៦៩.៥៥៦,៤៧ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយហាសិបប្រាំមួយ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលធ្វើជាកិច្ចសន្យាលក់ផ្តាច់ ។

**៣. ចំណុចវិវាទ និងចំណុចដែលគ្មានវិវាទ**

**៣.១ ចំណុចវិវាទ**

១.តើលិខិតលក់ផ្តាច់លេខ ១៣៩ សរលចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ គឺជាកិច្ចសន្យាទិញលក់ដី ឬជាកិច្ចសន្យាខ្ចីបរិភោគ?

២.តើលិខិតលក់ផ្តាច់លេខ ០០៥/១៥ សរលចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៥ គឺជាកិច្ចសន្យាទិញលក់ដី ឬជាកិច្ចសន្យាខ្ចីបរិភោគ?

**៣.២ ចំណុចដែលគ្មានវិវាទៈ** គ្មាន ។

**៤. ការអះអាងរបស់គាគី**

៤.១. ការអះអាងរបស់ដើមចោទ

អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ បានថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា កូនក្តីខ្លួន ទិញដីពីប្រជាពលរដ្ឋក្នុងអំឡុងឆ្នាំ ១៩៩៤ ដល់ ឆ្នាំ ១៩៩៦ ។ នៅឆ្នាំ ២០១១

ដើមចោទ ខ្ចះលុយបានទៅខ្ចីលុយឈ្មោះ [redacted] កញ្ញា ចំនួន៧០.០០០ (ប្រាំពីរម៉ឺន) ដុល្លារអាមេរិក ដោយបញ្ចាំដីទំហំ ៥៣.២២៥ (ប្រាំម៉ឺនបីពាន់ពីររយម្ភៃប្រាំ) ម៉ែត្រការ៉េ ដោយធ្វើជាកិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិលេខៈ១២៦០ សរល ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១ ។ នៅឆ្នាំ២០១៤ បានខ្ចីលុយម្តងទៀតពីឈ្មោះ [redacted] កញ្ញា ចំនួន២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកបន្ថែមទៀត ដោយដាក់បញ្ចាំដីទំហំ ៦៩.៥៥៦,៤៧ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយកៅសិបប្រាំមួយ) ម៉ែត្រការ៉េ ក្រោមរូបភាពជាកិច្ចសន្យាលក់ផ្តាច់លេខៈ១៣៩ សរល ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ ។ បានមួយថ្ងៃឈ្មោះ [redacted] កញ្ញា បានប្រគល់សិទ្ធិឲ្យដើមចោទ លក់ដីដែលបានដាក់បញ្ចាំនោះ ដើម្បីយកមកសងក្នុងរយៈពេល ៣ ខែ ដូចមានក្នុងលិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី០៣ ខែ មេសា ឆ្នាំ២០១៤។ មូលហេតុនៃការប្តឹងលុបនេះ កិច្ចសន្យាលក់ដីរវាង កូនក្តីខ្ញុំបាទ និងឈ្មោះ [redacted] កញ្ញា គឺជាការខ្ចីបញ្ចាំតែ ប៉ុណ្ណោះ មិនមែនជាការទិញលក់ពិតប្រាកដឡើយ ហើយកិច្ចសន្យាទិញលក់នេះ គឺគ្មានសុពលភាពផ្លូវច្បាប់ទេ ដូច្នេះ ឈ្មោះ [redacted] កញ្ញា ពុំមានសិទ្ធិលក់ដីរបស់កូនក្តីខ្ញុំបាទឡើយ ។

ចំណែកឈ្មោះ [redacted] សុន និងប្រពន្ធឈ្មោះ [redacted] គឿន ដែលបានធ្វើការផ្ទេរសិទ្ធិដីប្រាំប្លង់នេះ ដូចមានលិខិតផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជី មានក្នុងកម្មវត្ថុនៃពាក្យបណ្តឹងត្រង់ចំណុចទី ៩ ទៅឲ្យឈ្មោះ [redacted] មុន្នី និងប្រពន្ធឈ្មោះ [redacted] ពេជ្រលីនណា គឺគ្មានសិទ្ធិលក់ដីរបស់កូនក្តីខ្ញុំបាទទេ (ឈ្មោះ [redacted] សុន បានលក់ដីនេះបន្តទៅឲ្យឈ្មោះ [redacted] មុន្នី និង ប្រពន្ធឈ្មោះ [redacted] លីនណា) ។

៤.២. ការអះអាងរបស់សហចុងចម្លើយ

-អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ [redacted] កញ្ញា ធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលថា បដិសេធការទាមទាររបស់ដើមចោទ និងស្នើសុំលោកចៅក្រមលើកពាក្យបណ្តឹង ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២១ ចោល ។

៤.២.១.ស្នើសុំឲ្យចៅក្រមពិនិត្យអាជ្ញាយុកាលបណ្តឹងទាមទារ ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ព្រោះថាៈ ដើមចោទបានទទួលស្គាល់អង្គហេតុនេះ តាំងពី ឆ្នាំ២០១១ រហូត ឆ្នាំ២០១៥ តែក្រមរដ្ឋប្បវេណី បានកំណត់បណ្តឹងទាមទារមានអាជ្ញាយុកាល ៥ឆ្នាំ ដែលបណ្តឹងទាមទារនេះ ផុតអាជ្ញាយុកាល១ឆ្នាំជាងទៅហើយ ។

៤.២.២.ចំពោះឯកសារណបដែលភាគីដើមចោទប្រមូលទិញដីពីប្រជាពលរដ្ឋ គឺពុំដូចការអះអាងរបស់ភាគីដើមចោទឡើយ ។ ឯកសារទាំងនេះគឺកូនក្តីខ្ញុំបាទបាន ប្រគល់ទៅឲ្យភាគីសហចុងចម្លើយឈ្មោះ [redacted] សុន និង [redacted] គឿន ហើយឈ្មោះ នេះបានលក់ទៅបន្តទៅឲ្យឈ្មោះ [redacted] មុន្នី ដែលគេយកឯកសារណបនេះ ទៅកសាងប័ណ្ណកម្មសិទ្ធិរួចរាល់ហើយ ។

-អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ [redacted] សុន និងប្រពន្ធឈ្មោះ [redacted] គឿន ធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលថា ស្នើសុំតុលាការលើកបណ្តឹងរបស់ភាគីដើមចោទ សូមឲ្យតុលាការពិនិត្យលើអាជ្ញាយុកាលនៃបណ្តឹង ផ្ទៀងផ្ទាត់ពន្ធលើបណ្តឹងដើមចោទបានបង់ធៀបនឹងតម្លៃបានប្រកាសនៃបណ្តឹងទាមទារដោយមូលហេតុនៃបណ្តឹងនេះធ្វើឡើងមិន



Scanned with CamScanner

ពាក់ព័ន្ធនឹងកូនក្តីយើងខ្ញុំទេ ព្រោះការទិញដីរបស់កូនក្តីខ្ញុំ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ដូចមានចែងក្នុងកិច្ចសន្យាលក់ផ្តាច់លេខ ៣៤៥/ ១៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ និងលេខ៣៤៥/១៥ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ។

## សំអាងហេតុ

១.ដើមចោទដាក់ពាក្យបណ្តឹងសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម៖

១.១.លុបចោល កិច្ចសន្យាលក់ដី និងផ្ទេរសិទ្ធិកាន់កាប់លេខៈ ១២៦០ សរល ចុះថ្ងៃទី ១៨/០៨/២០១១ ។

១.២.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខ:០០៥/១៥ សរល ចុះថ្ងៃទី ២៣/០១/២០១៥។

១.៣.លុបចោល គំនូសបង្ហាញទីតាំងដីរបស់ឈ្មោះ [redacted] កញ្ញា ចុះថ្ងៃទី ០៣/០៤/២០១៤។

១.៤.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខ:១៣៩ សរល ចុះថ្ងៃទី ០៣/០៤/២០១៤។

១.៥.លុបចោល គំនូសបង្ហាញទីតាំងដីរបស់ឈ្មោះ[redacted]កញ្ញា ចុះថ្ងៃទី ០៣/០៤/២០១៤។

១.៦.លុបចោល លិខិតប្រគល់សិទ្ធិ ចុះថ្ងៃទី ០៣/០៤២០១៤។

១.៧.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខ:៣៤៥/១៥ ចុះថ្ងៃទី ៣១/១២/២០១៥។

១.៨.លុបចោល កិច្ចសន្យាលក់ផ្តាច់លេខ:៣៤៥/១៥ ចុះថ្ងៃទី ៣១/១២/២០១៥។

១.៩.លុបចោល លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីលេខ:១៤៧៧ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៧៨ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៧៩ ស.រ.ល ចុះថ្ងៃទី ២៥/ ០៩/២០២០, ១៤៨០ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០, ១៤៨១ ស.រ.ល ចុះថ្ងៃទី ២៥/០៩/២០២០។

១.១០.សុំសិទ្ធិកម្មសិទ្ធិលើដីទំហំ ៥៣.២២៥ (ប្រាំម៉ឺនបីពាន់ពីររយម្ភៃប្រាំ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

១.១១.សុំសិទ្ធិកម្មសិទ្ធិលើដីទំហំ ៦៩.៥៩៦,៤៧ (ប្រាំមួយម៉ឺនប្រាំបួនពាន់ប្រាំរយកៅសិបប្រាំមួយ) ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅ ភូមិកោះគ្របបាយ ឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

១.១២.សុំសំណងជម្ងឺចិត្ត និងសោហ៊ុយក្តីពីចុងចម្លើយសរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាម៉េរិក។

២.នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផលលើកទី២ ដែលបានកំណត់កាលបរិច្ឆេទនៅថ្ងៃទី ១០ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ៩ ព្រឹក ដោយបានចេញដីកាកោះហៅ និងអញ្ជើញមេធាវីគូភាគីត្រឹមត្រូវតាមនីតិវិធីច្បាប់ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១ ហើយភាគីដើមចោទដែលមាន [redacted] ច័ន្ទក្រិស្នា ជាមេធាវី តំណាងដោយអាណត្តិបានទទួលដីកា នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២។ ប៉ុន្តែភាគីដើមចោទពុំបានចូលតាមកំណត់កាលបរិច្ឆេទខាងលើឡើយ។ គប្បីតុលាការអនុវត្តតាមបញ្ញត្តិមាត្រា ២០០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣.នៅក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ តុលាការបានចេញដីកាកោះហៅ និងអញ្ជើញមេធាវីភាគីដើមចោទ ព្រមទាំងភ្ជាប់ជូននៅកំណត់ហេតុត្រៀមលើកទី២



Scanned with CamScanner

(ថតចម្លង) ដែលមានលោកមេធាវី [redacted] បានទទួល ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ប៉ុន្តែភាគីដើមចោទពុំបានចូលតាមកំណត់កាលបរិច្ឆេទខាងលើឡើយ គប្បីតុលាការអនុវត្តតាមបញ្ញត្តិមាត្រា ២០០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. ផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពន្ធជាបន្ទុករបស់អ្នកចាញ់ក្តី។

**សេចក្តីសម្រេចបញ្ចប់**

១-ច្រានចោលការទាមទាររបស់ដើមចោទ ក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ គ្រប់ចំណុចទាំងមូល។

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ កំបាំងមុខដើមចោទតែចាត់ទុកជាចំពោះមុខ និងចំពោះមុខភាគីសហចុងចម្លើយ។

-ទុកសិទ្ធឲ្យប្តឹងតវ៉ាតាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

**(បានចម្លងត្រឹមត្រូវតាមច្បាប់ដើម)**

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
កណ្តាលថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner